ភ្នំពេញ , ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៤

# ប្រកាស លេខ ១០ សកអ ៩៤

## ស្ដីពីសៀវភៅការងារ និង ប័ណ្ណការងារ

* * *

រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ការងារ

## សំរេច

**ប្រការ ១ :** នាយក ឬ ម្ចាស់សហគ្រាស ឬ គ្រឹះស្ថានណាក៏ដោយមិនអាចប្រើអ្នកស៊ីឈ្នួលដោយគ្មានកាន់សៀវភៅការងារឡើង ហើយត្រូវបង្កលក្ខណៈងាយស្រួលអោយគេមានលទ្ធភាពគ្រប់គ្រាន់ទៅធ្វើសៀវភៅការងារនៅនាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម នៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនចំពោះអ្នកនៅរាជធានីភ្នំពេញ និង នៅអធិការដ្ឋាន សង្គមកិច្ចការងារ និងអតីតយុទ្ធជន ខេត្ត ក្រុង នៃមូលដ្ឋានខ្លួនចំពោះអ្នកនៅខេត្ត ក្រុងដទៃទៀត ។

**ប្រការ ២ :** ចំពោះជនកម្ពុជា

នៅពេលទៅសុំសៀវភៅការងារត្រូវយកទៅជាមួយនូវ :

- ពាក្យសុំសៀវភៅការងារ បិទតែមប្រិយ៍ ១៥០៛ .................................. ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតបញ្ជាក់ទីលំនៅ ( ចំពោះអ្នកស៊ីឈ្នួលណាគ្មានអត្តសញ្ញាណប័ណ្ណ ) .................................................... ០១ ច្បាប់
- លិខិតបញ្ជាក់ពីមុខរបរដែលបានចេញអោយដោយនាយក ឬ ម្ចាស់សហគ្រាស ឬ គ្រឹះស្ថានសាមី ដូចមានគំរូជាឧបសម្ព័ន្ធ នៃប្រកាសនេះ ........................ ០១ ច្បាប់
- រូបថតទំហំ ៤ × ៦ ស.ម ចំនួន ................................................ ០៣ សន្លឹក

អាករសៀវភៅការងារនេះ ត្រូវបានកំណត់អោយ [illegible] ៥០០ រៀល ( មួយពាន់ប្រាំរយរៀល ) គត់ ។

**ប្រការ ៣ :** – ចំពោះជនបរទេស

ក– អ្នករស់នៅក្រៅប្រទេសកម្ពុជា ហើយចូលមកក្នុងកម្ពុជាក្នុងគោលបំណងប្រកបមុខរបរនានាត្រូវមកធ្វើសៀវភៅការងារ និង ប័ណ្ណការងារជាមុន ដោយត្រូវយកមកជាមួយនូវ៖

- ពាក្យសុំសៀវភៅ និង ប័ណ្ណការងារបិទតែមប្រ៉ៃ ១៥០៛ ..................... ០១ ច្បាប់
- លិខិតឆ្លងដែន ..................... ០១ ច្បាប់
- ប័ណ្ណស្នាក់នៅត្រឹមត្រូវ ..................... ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមាយាទល្អ និង កិត្តិយសល្អ ដែលចេញអោយដោយក្រសួងមានសមត្ថកិច្ច នៃប្រទេសខ្លួន ..................... ០១ ច្បាប់
- លិខិតបញ្ជាក់កាយសម្បទាល្អ និង សុខភាពល្អចេញដោយនាយកដ្ឋានពេទ្យការងារ ចំនួន ..................... ០១ ច្បាប់
- រូបថត ៤ × ៦ ស.ម ចំនួន ..................... ០៤ សន្លឹក

ខ– ជនបរទេសរស់នៅអចិន្ត្រៃយ៍ ក្នុងប្រទេសកម្ពុជាទាំងអស់ត្រូវតែមានសៀវភៅការងារ និងប័ណ្ណការងារ ។ នៅពេលមកធ្វើសៀវភៅនិងប័ណ្ណការងារត្រូវយកមកភ្ជាប់មកជាមួយនូវ៖

- ពាក្យសុំសៀវភៅ និង ប័ណ្ណការងារ បិទតែមប្រ៉ៃ ១៥០៛ ..................... ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍ ចំនួន ..................... ០១ ច្បាប់
- រូបថត ៤ × ៦ ស.ម ចំនួន ..................... ០៤ សន្លឹក

ក្នុងចំណុច ក និង ខ នៃប្រការនេះ ជនបរទេសត្រូវបង់ អាករសៀវភៅការងារ និងប័ណ្ណការងារជារៀងរាល់ឆ្នាំដោយកំណត់ ១០.០០០៛ ( ដប់ពាន់រៀល ) ក្នុងមួយឆ្នាំ ។ ចំពោះអ្នករស់នៅអចិន្ត្រៃយ៍ត្រូវបង់អាករនេះ អោយបានមុនបំណាច់ខែ មិនា នៃ ឆ្នាំទីមួយ ៗ ។

**ប្រការ ៤ :** ជនបរទេសណាដែលមិនបានបង់អាករសៀវភៅ និង ប័ណ្ណការងារអោយបានតាមការកំណត់ខាងលើត្រូវពិន័យទ្វេឡើងមួយជាពីរ ទៅតាមចំនួនឆ្នាំដែលខកខានមិនបានបង់ ។

**ប្រការ ៥ :** អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិទាំងអស់នៃប្រការនេះត្រូវពិន័យ ឬ ទទួលទោសតាមបញ្ញត្តិនៃមាត្រា ២៨៦ និង ២៨៨ នៃច្បាប់ការងារ ។

**ប្រការ ៦ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ឌីន ខែម